49

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ.......

រាជធានីភ្នំពេញ, ថ្ងៃទី.....ខែ.....ឆ្នាំ២០០.....

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីការកែលំអការលើកទឹកចិត្តបុគ្គលិក នៅក្នុងវិស័យសុខាភិបាល

រដ្ឋមន្ត្រីក្រសួងសុខាភិបាល សូមធ្វើសេចក្តីប្រកាសពតិមានខាងក្រោម :

"រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់ជាសំខាន់លើលទ្ធភាពក្នុងការធានាថា សេវាសុខាភិបាល ដែលមានប្រសិទ្ធភាព និងមានគុណភាពខ្ពស់ ត្រូវបានផ្តល់ជូនដល់ប្រជាជនគ្រប់ស្រទាប់វណ្ណៈនៅក្នុងប្រទេសកម្ពុជា។ យើងនៅមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីសំរេចគោលដៅទាំងនេះ។ ហើយយើងនឹងមិនអាចសំរេចគោលដៅទាំងនេះ ដោយគ្មានបុគ្គលិក ដែលមានជំនាញគ្រប់គ្រងខ្ពស់ និងមានការប្តេជ្ញាក្នុងការផ្តល់សេវាសំខាន់ៗ បានទេ ។

អស់រយៈពេលជាច្រើនឆ្នាំមកហើយ ដែលអត្រាប្រាក់បៀវត្សរ៍ទាប បានរារាំងបុគ្គលិករបស់យើង ដែលមានសមត្ថភាពនៅគ្រប់ថ្នាក់ មិនអោយលះបង់ពេលវេលារបស់ខ្លួនអោយអស់ពីចិត្ត ដើម្បីបំពេញកិច្ចការផ្លូវការ របស់ពួកគេ នៅក្នុងក្រសួងសុខាភិបាលបាន។ នៅពេលជាមួយគ្នានេះដែរ ប្រព័ន្ធគ្រប់គ្រងដែលនៅទន់ខ្សោយ បានធ្វើអោយពួកគេមាន ការពិបាកក្នុងការធានាក្នុងប្រសិទ្ធភាព ការងាររបស់ខ្លួន និងការអនុវត្តន៍តាមទិសដៅសំខាន់ៗរបស់ក្រសួង។ សំណើដែលកំពុងតែត្រូវបានរៀបចំឡើង សំរាប់គំរោងលើកទឹកចិត្តឱ្យកាន់តែប្រសើរឡើង របស់ក្រសួងនេះ នឹងជួយដោះស្រាយបញ្ហាទាំងនេះបាន ។

សំណើទាំងនេះ នឹងផ្តល់នូវដំណោះស្រាយថ្មីមួយ ដែលក្នុងនោះ ការដំឡើងបៀវត្សរ៍សំរាប់មុខតំណែងតាមចំនួនកំណត់ នឹងអាចធ្វើអោយបុគ្គលិក ធ្វើការពេញម៉ោងក្នុងការបំពេញមុខងារសំខាន់ៗរបស់ក្រសួង។ ជាថ្នូរមកវិញយើងនឹងតំរូវឱ្យពួកគេ បោះបង់ចោលការងារ និងប្រភពប្រាក់បំណាច់ផ្សេងទៀត ហើយធ្វើការនៅក្នុងក្របខ័ណ្ឌដែលគ្មខ័ណ្ឌបំពេញ ការងារប្រចាំឆ្នាំ ដែលមាននៅក្នុងកិច្ចសន្យាការងារថ្មី។ វិធានការគ្រប់គ្រងរឹងមាំ នឹងត្រូវបានរៀបចំឡើង ដើម្បីដោះស្រាយជាមួយអ្នកដែលមិនបានអនុវត្តតាមអ្វីដែលខ្លួនបានព្រមព្រៀង ។

ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល, លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម, ទូរស័ព្ទ-ទូរសារ (៨៥៥-២៣) ៨២៦ ០៣៤/៨២៦ ៨៤១, ទូរស័ព្ទ (៨៥៥-២៣) ៧២២ ៩៣៣

ឱកាសប្រកួតប្រជែងសំរាប់មុខតំណែងដែលទទួលបានបៀវត្សរ៍ខ្ពស់នេះ នឹងផ្តល់ជូនដល់បុគ្គលិកណា ដែលមានបំណងចូលរួមការប្រកួតប្រជែង ។

ថ្ងៃនេះ ខ្ញុំសូមអនុញ្ញាតអោយថ្នាក់ដឹកនាំជាន់ខ្ពស់របស់ក្រសួងសុខាភិបាល បន្តអនុវត្តដំណាក់កាលការងារបន្តបន្ទាប់របស់ខ្លួន ដើម្បីអនុវត្តនូវសំណើទាំងនេះ ដែលរួមទាំងការបញ្ចប់ការពិនិត្យឡើងវិញ លើការពិភាក្សាមុខងារ ការអភិវឌ្ឍន៍ក្របខ័ណ្ឌគ្រប់គ្រងបំពេញការងារ និងការកែលំអនីតិវិធីប្រកាស និងជ្រើសរើស បុគ្គលិកផង។ សេចក្តីប្រកាសបន្ថែមទៀតអំពីសមាសធាតុផ្សេងៗរបស់គំរោង និងកាលវិភាគសំរាប់ការអនុវត្តន៍ នឹងត្រូវធ្វើឡើងនៅពេលដែលពតិមានលំអិត ត្រូវបានផ្តល់ ក្រោយពីការពិភាក្សា និងពិគ្រោះយោបល់ បន្ថែម ។

ខ្ញុំមានទស្សនវិស័យ ក្នុងការលើកកំពស់ក្រសួងសុខាភិបាល ដែលធ្វើអោយយើងមានបុគ្គលិកជំនាញសមស្រប សំរាប់ធ្វើការជាមួយប្រព័ន្ធសមស្រប ដើម្បីផ្តល់សេវាសុខាភិបាលដល់ប្រជាជនកម្ពុជា ដែលរួមទាំងអ្នកដែលរស់នៅក្នុងតំបន់ដាច់ស្រយាល និងក្រីក្របំផុតនៅក្នុងប្រទេសរបស់យើងផងដែរ ។ សកម្មភាពដែលបានអនុម័តនេះនឹងផ្តោតសំខាន់ដល់បណ្តាមន្ត្រីដែលបំរើការងារអាទិភាពសំរាប់ការកាត់បន្ថយភាពក្រីក្រពិសេសសុខភាពមាតា និង ទារក និង ការប្រយុទ្ធនឹងជំងឺឆ្លង ។

"ការងារកំណែទំរង់ទាំងនេះ នឹងនាំផ្លូវយើង ទៅសំរេចបាននូវទស្សនវិស័យនេះ" ៗ

វេជ្ជ. នុត-សុខុម



ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល. លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម. ទូរស័ព្ទ-ទូរសារ (៨៥៥-២៣) ៤២៦ ០៣៤/ ៤២៦ ៨៤១. ទូរស័ព្ទ (៨៥៥-២៣) ៧២២ ៩៣៣

**MINISTRY OF HEALTH**
**No. ..............................**

**KINGDOM OF CAMBODIA**
**Nation Religion King**

**Phnom Penh....../......../ 200...**

## PRESS RELEASE

### IMPROVING WORKFORCE INCENTIVES IN THE HEALTH SECTOR

The Minister for Health today made the following statement:

"The Royal Government of the Kingdom of Cambodia places great importance on being able to ensure that efficient, high quality health services are available to all of the nation's people. We still have a great deal to do to achieve this goal. And we shall never be able to reach it without a highly-skilled and well-managed workforce which is dedicated to delivering essential services.

Over several years a situation has developed in which extremely low pay prevents many of our best staff at all levels from devoting themselves wholeheartedly to their official duties in the Ministry of Health. At the same time, weak management systems make it difficult for them to ensure that their work is always effective, and directed towards achieving the Ministry's key objectives. The proposals which are now being developed for an improved incentive scheme for the Ministry will help to tackle these problems.

These proposals will offer a new deal, in which for a restricted number of posts enhanced pay will be available which will permit staff to work full-time on delivering the Ministry's core functions. In return, we will require them to give up other forms of employment and sources of remuneration, and to work within the framework of an annual performance agreement backed up by a new contract of employment. Firm management action will be taken to deal with those who do not keep their side of the bargain.

The opportunity to compete for posts entitled to enhanced pay will be available to all staff who wish to do so.

I have authorized senior managers in the Ministry to proceed with the next stages of the work needed to implement these proposals, including the completion of functional reviews, the development of the performance management framework, and an overhaul of recruitment and selection procedures. Further announcements about the various elements of the scheme and the timetable for implementation will be made as soon as the details have been confirmed, following further discussion and consultation.

I have a vision of an improved Ministry in which we have the right number of staff with the right skills working with the right systems, to deliver the health services that the people of Cambodia – including those living in the most remote and poorest parts of our country – need. The actions approved will target health personnel working in priority areas to reduce poverty and especially improve maternal and child health and communicable disease control. These reforms will take us some way towards realizing that vision.

Dr. NUTH SOKHOM
Minister of Health